**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

## សូមជម្រាបជូន

លោកជំទាវ **សួស ណារ៉ា ហ៊ឹម ឆែម** ព្រមទាំងក្រុមគ្រួសារ

ខ្ញុំនិងភរិយា មានសេចក្តីក្តុកក្តួល និងសោកស្តាយក្រៃលែងបន្ទាប់ពីបានទទួលដំណឹងដ៏រន្ធត់ក្រៀមក្រំអំពីមរណភាពរបស់ ឯកឧត្តម **ហ៊ឹម ឆែម** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស និងជាអតីតរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា កាលពីថ្ងៃសៅរ៍ ១០រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ១០:៥៥ នាទីព្រឹក ក្នុងជន្មាយុ ៨២ឆ្នាំ ដោយរោគាពាធ។

ការទទួលមរណភាពរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ហ៊ឹម ឆែម** គឺជាការបាត់បង់ដ៏ធំធេងនូវស្វាមីប្រកបដោយសង្គហធម៌ដ៏ល្អ និងជាការបាត់បង់ឪពុក ជីតា ប្រកបដោយព្រហ្មវិហារធម៌មិនចេះរីងស្ងួត ព្រមទាំងការបាត់បង់នូវវីរកុលបុត្រខ្មែរដ៏ឆ្នើមមួយរូប ដែលពោរពេញដោយឆន្ទៈ មនសិការក្នុងការបំរើបុព្វហេតុ **ជាតិ សាសនា ព្រះមហាក្សត្រ** គ្រប់កាលៈទេសៈ ពិសេសបានរួមចំណែកយ៉ាងសកម្មក្នុងការលើកស្ទួយតម្លៃវប្បធម៌ ព្រះពុទ្ធសាសនា ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ក្នុងឱកាសដ៏ក្រៀមក្រំបំផុតនេះ ខ្ញុំនិងភរិយា សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធសព ឯកឧត្តម ទេសរដ្ឋមន្ត្រី **ហ៊ឹម ឆែម** បានសោយសុខក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ។

សូមលោកជំទាវ និងក្រុមគ្រួសារនៃសព ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ថ្ងៃ ចន្ទ ១២ រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០

**ប្រាក់ សុខុន**


អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh